ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

លេខៈ ០១១ / សសរ.អ.ជ.ប.គ.៣ / ១៩

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតការិយាល័យ ទំនាក់ទំនងព្រំដែន

Border Liaison Office ( BLO )

## អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៥៧ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- សេចក្តីសម្រេចលេខ០០២/០២សសរ.អ.ជ.ប.គ.៣.ចុះថ្ងៃ១៧ ខែកក្កដា ឆ្នាំ២០០២ ស្តីពីការបង្កើតការិយាល័យទំនាក់ទំនងព្រំដែន BLO
- សេចក្តីសម្រេចលេខ០០១/១៣សសរ.អ.ជ.ប.គ.៣.ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលសមាសភាពតួនាទី និងភារកិច្ចការិយាល័យទំនាក់ទំនងព្រំដែន
- យោងតាមការចាំបាច់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

# សម្រេច

**ប្រការ ១**: ត្រូវបានបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (BLO) ចំនួន១៩ កន្លែង រួមមាន:

| | |
|---|---|
| ១. ការិយាល័យ BLO បាវិត | ខេត្តស្វាយរៀង |
| ២. ការិយាល័យ BLO ក្អមសំណរ | ខេត្តកណ្តាល |
| ៣. ការិយាល័យ BLO ជ្រៃធំ | ខេត្តកណ្តាល |
| ៤. ការិយាល័យ BLO ភ្នំដិន | ខេត្តតាកែវ |
| ៥. ការិយាល័យ BLO ព្រែកចាក | ខេត្តកំពត |
| ៦. ការិយាល័យ BLO ចាំយាម | ខេត្តកោះកុង |
| ៧. ការិយាល័យ BLO ព្រំ | ខេត្តប៉ៃលិន |
| ៨. ការិយាល័យ BLO ដូង | ខេត្តបាត់ដំបង |
| ៩. ការិយាល័យ BLO ប៉ោយប៉ែត | ខេត្តបន្ទាយមានជ័យ |
| ១០. ការិយាល័យ BLO ជាំ | ខេត្តឧត្តរមានជ័យ |
| ១១. ការិយាល័យ BLO អូរស្មាច់ | ខេត្តឧត្តរមានជ័យ |
| ១២. ការិយាល័យ BLO ជប់គគីរ | ខេត្តឧត្តរមានជ័យ |
| ១៣. ការិយាល័យ BLO កំពង់ស្រឡៅ | ខេត្តព្រះវិហារ |
| ១៤. ការិយាល័យ BLO អានសេះ | ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ |
| ១៥. ការិយាល័យ BLO កោះឈើទាលធំ | ប្តូរទៅភូមិអូរស្វាយ ខេត្តស្ទឹងត្រែង |
| ១៦. ការិយាល័យ BLO ដុងក្រឡ | ប្តូរទៅត្រពាំងគ្រៀល ខេត្តស្ទឹងត្រែង |
| ១៧. ការិយាល័យ BLO ព្រះរំកិល | ខេត្តស្ទឹងត្រែង |
| ១៨. ការិយាល័យ BLO អូយ៉ាដាវ | ខេត្តរតនគិរី |
| ១៩. ការិយាល័យ BLO ត្រពាំងផ្លុង | ខេត្តត្បូងឃ្មុំ |

**ប្រការ ២**: ការិយាល័យទំនាក់ទំនងព្រំដែន (Border Liaison Office) មានសមាសភាពដូចខាងក្រោម ដែលទីតាំងការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត ។

| | |
|---|---|
| ១. អភិបាលរងខេត្ត | ០១រូប ប្រធាន |
| ២. ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្ត | ០១រូប អនុប្រធានអចិន្ត្រៃយ៍ |
| ៣. អភិបាលក្រុង-ស្រុកជាប់ព្រំដែនអន្តរជាតិដែលមានការិយាល័យ BLO | អនុប្រធាន |
| ៤. ប្រធានស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិ | អនុប្រធាន |
| ៥. តំណាងមន្ទីរប្រឆាំងគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ៦. នាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ប្រចាំច្រកទ្វារព្រំដែនអន្តរជាតិ | សមាជិក |
| ៧. ប្រធានទីស្នាក់ការគយ និងរដ្ឋាករប្រចាំច្រកទ្វារព្រំដែនអន្តរជាតិ | សមាជិក |
| ៨. នាយសេនាធិការកងរាជអាវុធហត្ថខេត្ត | សមាជិក |
| ៩. ប្រធានវរនគរបាលការពារព្រំដែនគោក | សមាជិក |
| ១០. ប្រធានវរនគរបាលការពារព្រំដែនទឹកខេត្តមាន (BLO ជាប់សមុទ្រ) ០១រូប | សមាជិក |

សមាសភាពជាក់ស្តែងរបស់ការិយាល័យទំនាក់ទំនងព្រំដែន BLO ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**ប្រការ ៣**: ការិយាល័យទំនាក់ទំនងព្រំដែន BLO មានតួនាទី និងភារកិច្ចដូចខាងក្រោម:

- សហការជាមួយការិយាល័យទំនាក់ទំនងព្រំដែនរបស់ប្រទេសជាប់ព្រំដែន និងមន្ត្រីអនុវត្តច្បាប់ដែលពាក់ព័ន្ធក្នុងការផ្តល់ព័ត៌មានឲ្យគ្នាទៅវិញទៅមក ដើម្បីទប់ស្កាត់ បង្ក្រាបការចរាចរគ្រឿងញៀន និងសារធាតុគីមីផ្សំខុសច្បាប់ ។
- សហការសម្របសម្រួលការងារបន្ថែមជាមួយគម្រោងអនុតំបន់ស្តីពីភាពជាដៃគូ នៃមន្ត្រីអនុវត្តច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ហៅកាត់ថា PATROL ។
- សហការសម្របសម្រួលការងារពាក់ព័ន្ធភូមិ ឃុំ សង្កាត់ ស គ្មានគ្រឿងញៀននៅតាមព្រំដែន។
- ដឹកនាំប្រជុំត្រួតពិនិត្យការងារ និងរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ និងតាមករណីនីមួយៗ មកអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- អនុវត្តតួនាទី និងភារកិច្ចផ្សេងៗទៀត តាមការសម្រេចរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**ប្រការ ៤**: អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមានភារកិច្ច ជំរុញសម្របសម្រួល ដឹកនាំគ្រប់គ្រងការអនុវត្តរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ដូចមានចែងក្នុងប្រការ២ខាងលើ ។

**ប្រការ ៥**: រាល់សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦**: រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋមន្ត្រីក្រសួងជាសមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គស្នងការដ្ឋាននគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែទុតិយាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ កក្កដា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន**

**ចម្លងជូន:**

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ

-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

-ប្រការ១ និងប្រការ៦

-ឯកសារ-កាលប្បវត្តិ